Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃចន្ទ ពុធ សៅរ៍



អ្នកប្រែសម្រួល : អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ១

## ខគ្គទី ១

## ភូនស្នូមអនាថា

ព្រះទិនករជ្រៀតជ្រែសន្សឹម ៗ ទៅទិសខាងលិច ពោលរស្មីក្រហមឆ្អៅលើផែនពសុធា . . .

ភូមិហ្វូវជាន ជាទីជនបទមួយដ៏តូច ពេ ភូមិតាំងឡាយ ខ្លះរែកអុស ខ្លះលីចប, នង្គ័ល កន្ត្រកបន្លែសាច់ ខ្លះសែងត្រីតាំងកន្ត្រោង ៗ សំដៅទៅភូមិឋានរៀង ៗ ខ្លួន ៗ

សាយណ្ហកាលកំពុងប្រព្រឹត្តទៅ ក្នុងបរិយាកាសដ៏សែនរីករ ស្រាប់តែលាន់ឮស្នូរជើងសេះណ្ដុំគ្នាល្វើយ ៗ មកពីទិសខាងលិច គ្មានអ្នកណាចាប់អារម្មណ៍នឹងស្នូរជើងសេះនេះទេ ព្រោះហ្វូវជានជា ផ្លូវគមនាគមន៍យ៉ាងសំខាន់ តែងមានឈ្មួញជិះសេះទៅមកជាធម្មតា ស្នូរស័ព្ទលាន់រំពងកាន់តែច្បាស់ឡើង ៗ រំពេចនោះ គេឃើញជនមួយក្រុមបំបោលសេះយ៉ាងគគ្រឹកគគ្រេងតម្រង់មកហ្វូវជាន អ្នកភូមិហាក់ភ្ញាក់ផ្អើល ស្រែកប្រាប់គ្នាថា:

- ប្រហែលជាពួកទាហានហើយ !

មានខ្លះភិយ សៅឡា

- ឆាប់គេច ... ប្រយ័ត្នជាន់ស្លាប់អ៊ីយ !

ពេលនោះប្អូនជើងសេះ និងកញ្ចែលាយឡំគ្នា លាន់ឮគ្រលួចពីខាងកើត,ត្បូង,លិច,ជើង គ្រប់ជុំជិត ៗ

អ្នកភូមិស្រែឡាំងកាំងស្ងាំងស្ងៀម នឹកបារម្ភ:

- ហោះប្អូនទេដឹង ?

នាគៀមមួយប្រហមាត់ផ្លូវ កម្មករម្នាក់សៀនអណ្តាត ពោលតិច ១ ថា:

-អូយ ! ម៉ែអើយ ប្រហែលពួកបងប្រុសនោះមកហើយ !

ម្ចាស់គៀមភ័យឡើងស្លាយមុខ លើកដៃញីញ៉ីប្រុងខះក្បាលកម្មករនោះ ដោយប្រទេច:

- អាគេតាប់ ! មើចនិយាយផ្ដេសផ្ដាសម៉្លេះ ? បងប្រុសប្អូនប្រុសអ្វី ? បើពិតជាអស់លោកទាំងនោះមែន ជីវិត ... អាឯងក៏មិនគង់រង់ដែរ ៗ ម្យ៉ាងទៀត មិនដែលមានទោសកម្មថ្ងៃក្រឡែតដូច្នេះទេ ! អូយ ! ដូច .. ដូចជាចម្លែក ...

ពោលដល់ត្រឹមណេះតំហារលែងរួច ព្រោះផងស្នៀតពាក់ខ្មៅ ពាក់មួកហាមធំ ៗ មួន, ប្រាំនាក់ជិះសេះមកដល់ហើយប្រកាសថា :

បងប្អូនទាំងអស់គ្នា សូមនៅឲ្យស្ងៀមមួយកន្លែងកុំធ្វេចធ្វាចក្រែងកាំបិតគ្មានភ្នែកណា !

ស្រែកបណ្ដើរគេញាក់សេះទៅទិសខាងលិចបណ្ដើរ ៗ ជើងសេះរណ្ដំលើថ្មផ្លូវ បញ្ចេញស្នូរសំឡេងឮឡែត្រើរន្ទត់ ៗ នៅទិសខាងលិចផងខោអាវខ្មៅប្រាំបួននាក់លាក់មុខក្រោមមួកហាមធំ ៗ បំផាយសេះតម្រង់មកហើយដាក់លំកូវណ្ណ :

- បើចង់សុខស្រួលនៅស្ងៀម បើចង់ក្ស « ម៉ែសរវៃសកាំបិត » សូមចេញមុខមក !

កម្មករនៅក្នុងគៀមក្លាហានណាស់ ត្រហឹមហ៊ឹងហើយស្ទូ :

- "ម៉ែសវៃសកាំបិត» មានរសជាតិយ៉ាង ...

កម្មករនេះហ៊ុំលមេប៉ូចនិយាយច្រើនទៀត តែមិនទាន់អីផងក៏ត្រូវផងខោអាវខ្មៅពាក់វ៉ាក់វ៉ាក់ផាប់ ។ ផងនោះជាល់វិប កម្មករក៏សក់ផ្លុលពីលើប្រត្យប់ចេញពីក្នុងគៀម ហើយត្រូវគេបញ្ជាជំនិះអូសទៅមុខជាបន្ទាន់កម្មករកេញត្រូវសេះរបស់ពួកខោអាវខ្មៅជាន់ស្លាប់យ៉ាងអាណោចអាធ័ម ៗ អ្នកភូមិឃើញពួកជិះសេះមានចិត្តឃោរឃៅកាចសាហាវដូច្នេះ ក៏រឹតតែខ្វះឋរច្ចាប ៗ ខ្វះចង់ស្ទុះទៅបិទទ្វារ ភ្នែកម្រ៉ែកជើងមិនរួច ៗ

នៅចុងផ្លូវ មានតៀមមួយលក់នំបុ័ងខ្ទាញ់ ។ ពេលនេះខ្ទាញ់ក្នុងខ្ទះកំពុងពុះផុល ៗ ហើយនំខ្ទះទើបនឹងស្រង់ឡើងថ្មី ៗ មើលទៅគួរស្រក់ទឹកមាត់ ។ អ្នកធ្វើនំគឺតាចាស់ម្នាក់ ខ្ទិនគេង ។ គាត់ទនលុញមេម្សៅមីចង់ធ្វើជានំមូលៗ សង្កត់នឹងបន្ទះក្ដារឲ្យសំប៉ែត ចាប់លូមក កេយ ហើយបង់ទៅក្នុងខ្ទះ ។ តាចាស់អង្គុយបំពងនំយ៉ាងស្ងៀមស្ងាត់ ហាក់គ្មានអើពើនឹងព្រឹត្តិការណ៍ដ៏ខ្លោចផ្សាអម្បាញ់មិញនោះ ។

សូរកង្ហា និងជើងសេះរលត់ឈឹងសូន្យ សភាពស្ងប់ស្ងាត់បានលាតសន្ធឹងខ្លួនយ៉ាងរហ័ស សង្កត់ចុះពាយទៅលើភូមិដែលមានមនុស្សម្នាកប់រយនាក់នេះ សូម្បីកូនក្មេងកំពុងស្រែកយំក៏ប៉ាក់ហាក់ដូចគេចុកដែរ ។

ក្នុងសភាពដ៏ស្ងាត់ជ្រងំនេះ ស្រាប់តែលេចឮសូរជើងទុប ! ទុបយ៉ាងធ្ងន់ធ្ងរ សមាំលិច ៗ សូរជើងនោះ ហាក់ដូចកំពុងជាន់លើទ្រូងអ្នកភូមិស្រុក . . . មិនយូរប៉ុន្មាន ក៏អណ្ដែតស្រមោលមនុស្សម្នាក់ចាំងលើផ្លូវ , មានទ្រង់ទ្រាយវែងលយទៅមុខ ។ អ្នកផងទាំងឡាយក៏យកក្ដាមទៅជាឈរ ដ្ឋឹងលែងកម្រើកខ្លួនប្រាណរួច នៅសល់តែតាចាស់តែម្នាក់ប៉ុណ្ណោះ ដែលអង្គុយធ្វើនំបង់ខ្ទាញ់ដដែល.

សូរជើងនោះឈប់នឹងត់នៅមាត់ទ្វារផ្ទះតាលក់នំ ហើយជននោះពិនិត្យមើលតាតមតាំងពីក្បាលរហូតដល់ចុងជើង ៗ មួយសន្ទុះ ទើបគេគ្រហឹមហ៊ឺៈ ។ ! តាលក់នំងើបមុខសម្លឹង ៗ ឃើញអ្នកឈរនៅចំពោះមុខគាត់នោះ មានមាឌធំខ្ពស់អាយុប្រមាណ សែសិបប៉ាយឆ្នាំ ភ្នែកតូចតែមានពន្លឺខ្លាំងណាស់ ។ តាចាស់លក់នំងក់ក្បាលពោលទាំងញញឹមៈ

- លោកត្រូវការទិញនំឬ ? នំមួយតម្លៃ ៩ រៀល !

- ពោលផងយកដង្កៀបចាប់នំចេញពីក្នុងខ្ទះខ្ទាញ់ដាក់លើក្ដារ ។ ជនមាឌធំខ្ពស់នោះ សើចចំអកតិចៗ គំហកថាៈ

- យកមក !

ព្រមទាំងលូកដៃទន្ទេញទៅផង ៗ តាចាស់ឆ្លើយ បាទ ! ហើយចាប់នំដែលទើបនឹងស្រង់ពីខ្ទះនោះដាក់ទៅក្នុងបាតដៃជននោះ ! ជននោះជ្រួញចិញ្ចើមស្រែកគំហកទៀត

- ប៉ះ ! ដល់ពេលនេះហើយ ឯងនៅហ៊ានលេងតាកកំប្លុកដាក់យើងទៀតឬ ?

ពោលហើយចាប់នំនោះពោលតម្រង់តាចាស់លាន់ស្វូវ !

នំម្សៅទន់មែនតែមានសន្ទុះខ្លាំងណាស់បើពោលត្រូវច្បាស់ជាមានរបួសពុំខាន ៗ តាចាស់ផ្លៀងក្បាលគេចផុត ពុះបួរតែជាំង ! នំនោះធ្លាក់ទៅលើដីក្បែរចង្ក្រានទឹក ! បន្ទាប់ពីពោលនំនោះហើយជនចំឡែកដកទម្ពក់មួយគូយ៉ាងវែងចេញមកស្រែកគំរាមទៀតថា:

-ហ៊ឺះ ! ឯងចំណាក់ផល់ណាទៀត ! នែជនត្រកួលវ៉ូ ! យកក្បាលមក !

តាចាស់លក់នំបើកភ្នែកព្រឹមៗតបថា :

-ពួជាម្ចាស់ដំរាននៃដំរាំប៉ាតមាសចេះមួនអ្នកមានជួយអ្នកក្រ ! កាលបើអ្នកគុនទិយមរំពុកឈ្មោះគាត់ម្តងៗគេតែងសរសើរគាត់មិនដាច់ពីមាត់ ហេតុអ្វីក្មេងៗដែលគាត់ប្រើមកនេះ បែរជាគេរៀនខឹងមនុស្សលក់នំ បង់ខ្ញាញ់ទៅវិញ ?

សំឡេងគាត់ពុខ្សាវដូចជាអស់កម្លាំង តែពាក្យសំដីមួយម៉ាត់ៗច្បាស់លាស់ណាស់ ។ ចំណែកជនដែលមានមាឌធំខ្ពស់នោះ ពុតនេះហៅខ្លួនថាជាក្មេងៗនៃដំរាំប៉ាតមាសគឺ បង់ចំពៀមកាន់តែសំដែងនូវអាការខឹងក្រេវក្រោធឥតឧបមា, គំហកថា:

- វ៉ូតាអ៊ី ! ឯងពិតជាមិនព្រមយកចេញមកឬ?

តាលក់នំពុគេហៅចំឈ្មោះរបស់ខ្លួនបុកពោះគិប ! ឆឹកថា:

- ពួកកាំបិតមាសទទួលដំណឹងឆាប់មែន !

តែគាត់នៅក្បោទឹកមុខខ្ចិលច្រអូសសួរទៀតថា :

- លោកកាន់ទម្ពក់មួយគូដូច្នេះ ប្រហែលឈ្មោះទម្ពក់ដែក លី-លីតាយានហើយ ?

តាមពិតជននេះឈ្មោះលីតាយាន, មានរហស្សនាមថាទម្ពក់ទិព្វ ។

លុះពុវ៉ូតាអ៊ីតែរហស្សនាមខ្លួនថាទម្ពក់ដែក ក្នុងគំនិតមើលងាយបន្ទាបគាត់ដូច្នេះ, គាត់កាត់ក្រាំលែងបានក៏យារទម្ពក់ខាងធ្វេងប្រើស្ទៀត« លូកដៃចាប់មក»ថ្ពក់ស្មាធ្វេងវ៉ូតាអ៊ីក្លាម ។ តាគមលក់នំគេចផុតទៅខាងធ្វេង ។ លីតាយានដកដៃមកវិញរួចចាក់ទៅកញ្ចុំងសក់ទៀត ។

វ៉ូតាអ៊ីប្រញាប់បន្ទន់ខ្លួនគេចយារជើងស្តាំចាក់ម៉ុងទៅលើចង្ក្រាន ៗ ក្រើតក្លឹងកំពុងនេះឡេងក្រហមឆ្អៅនោះ ប៉ើងទៅលើលីតាយាន ហើយនំនិងខ្លាញ់ពុះមួយខ្ទះ កំស្រោចទៅលើគាត់ថ្ពៀនក្បាក់.

ទ្រុំប្រេ·

គាត់ស្រែកអូយ ! ខ្មាញ់ដែលកំពុងតែប្រុលនោះ ស្រាប់តែលើជើងគាត់ឈឺផ្សាជាអនេកៗ ឯក្មេងកំព្រាទ្រាំជើងបំប៉ោងខ្លួនលោតឡើងទៅលើដំបូលផ្ទះ ដោយកាន់ជាប់ស្នៀងទំនៅជាមួយផង ។

ពេលនោះកាំបិតមួយកាច់សំពងមកលើ គាត់ក៏ប្រញាប់លើកស្នៀងនឹងកាត់លាន់ស្នូរគឹង បែកផ្កាភ្លើងព្រាត ព្រោះស្នៀងគាត់នៅមិនតែធ្វើពីដែកថែបសុទ្ធ នឹងកាំបិតនោះខ្ទាតចេញវិញ ។ នៅពេលជាមួយគ្នានោះលំពែងមួយចាក់មកពីខាងឆ្វេង និង កាំបិតពីរកាប់មកពីខាងស្ដាំទៀត ។ ក្រៅអ៊ុំគ្រហឹមហ៊ឹះ ! ស្រែក :

- ប្រុតគ្នាដូច្នេះមិនចេះខ្មាសគេទេឬ ?

ពោលហើយ គាត់លោតទៅមុខចាប់ទាញស្នៀងដាច់ចេញជាពីរកំណាត់ក្លាយជាដំបងដែកមួយគូរង់កាត់លំពែងនិងកាំបិតទាំងគូនោះយ៉ាងស្និតស្នាញ ។ សត្រូវដែលឡោមព័ទ្ធគាត់ទាំងប៉ុន មានសំលៀកបំពាក់ដូចគ្នា ។

ឥឡូវក្រៅអ៊ុំឈរគ្រង់ខ្លួនទៅជាមានមាឌខ្ពស់មិនមែនតាចាស់គមខ្នងទៀតទេ ? គាត់បញ្ចេញវិជ្ជាគុនដក់ចុចតម្រង់ពីពេចសត្រូវគ្រប់ស្នៀតហើយ ទោះសត្រូវមានគ្នាប៉ុនាក់ក៏គាត់នៅតែមានរបៀបដាក់ដែរ គាត់ស្រែកត្រូវ ! បន្ទាប់នោះជនការទៅដែលកាន់លំពែងស្រែកអួយត្រូវមួយដក់ត្រង់ភ្លៅឆ្វេងរមៀលខ្លួនធ្លាក់ក្ដុកមកដី ។

លើដំបូលផ្ទះមានតាចាស់ស្គមតាបមួយរូបទៀតឈរទឹមបន្ទុះសន្តិតមើលធាកប្រយុទ្ធធ្វើហ៏ ។ គ្នមួយបំប្រួចភ្នែកប៉ុណ្ណោះ ក្រៅអ៊ុំវាយទម្លាក់ជាវជនម្នាក់ទៀត ហើយធ្លាក់បំប៉ុងជននោះមកក្រោមផង , នៅសល់តែជនម្នាក់កាន់កាំបិតដែលភ័យតក្កហណ្ណសំពៅហើយ តែគេនៅតំត្រដររដំយ៉ាងស្វិតស្វាញ ...

ឥឡូវតាចាស់ដែលមានកងស្គមតាបនោះបោះជំហានមួយៗ ចិតចូលជិតទូប្រយុទ្ធទាំងពីរដែលកំពុងត្រដរកាំបិតនិងដក់យ៉ាងស្វិតស្វាញ ។ ប៉ុន្តែគាត់ហាក់ឥតប្រហែសច្បាស់ជាប់រនឹងអាវុធពុំខាន តែតាចាស់នោះធ្វើដូចជាមើលមិនឃើញ , តម្រង់មករកគូប្រយុទ្ធទាំងពីរ ។ ខណៈនោះជនការទៅដែលប្រើកាំបិតមួយគូកំពុងប្រយុទ្ធនោះស្រែកឡើងថា:

- លោកគ្រូមាប្រយ័ត្ន !

គាត់ស្រែកស្ទើរមិនទាន់ផុតពីមាត់ផង, កាំបិតមួយដ៏ផ្លុលកាប់សំដៅស្មាតាចាស់ភ្លាមតែតានេះលើកដៃ

ស្ទាំផ្ទាត់ខ្លួនកាំបិតរបូតពីដៃផងនោះ ប៉ុន្តែត្រឡប់ត្រឡប់ទន្ទឹលហក់ការ ហើយធ្លាក់ដល់ដី លាន់សូរតឹង ៗ ជនអាវខ្មៅក៏យកកស្ទុតក្រៃលែង ៗ

វូគារស៊ីទ្រៀតចាក់តម្រង់ពោះគូប្រយុទ្ធជាបន្ទាន់ តែតាដែលស្គមចាបនោះលើកដៃស្ដាំចាប់ស្មា ផងនោះទាញទៅក្រោយខ្លួនហើយដៃម្ខាងទៀតលូកម្រាមចុចតម្រង់ក្នុងម្ខាងនៃវូគារស៊ី ៗ កាយវិការ គាត់រហ័សជាទីបំផុត ធ្វើឲ្យវូគារស៊ីរលះរលាំងដកដក់រងគាត់វិញ ៗ តាចាស់នោះបំបែរដៃចាក់ តម្រង់បំពង់កគាត់ទៀត, គាត់វាល់ច្រករងកាត់មិនទាន់ក៏ថយក្រោយមួយជំហាន តែតាចាស់មិន ទៅស្មៀមបោះជំហានតាមកិតព្រមទាំងយារម្រាមចុចតម្រង់ក្បាលពោះគាត់វិញ ៗ

វូគារស៊ីដែលប្រើដកទាំងគូក៏ស្គាល់ជំនាញខាងវិជ្ជាចុចជីពចរដែរ ទោះជាចុងម្រាមតានោះមិនមែន ចុចតម្រង់ជីពចរសំខាន់ក្នុងខ្លួនក៏គាត់មិនហ៊ានឲ្យម្រាមដៃតានោះប៉ះសាច់ឡើយ ៗ គាត់ប្រញាប់គ្រវី ដកវូកម្រង់ក្បាលតាចាស់វិញ ៗ តាចាស់ដែលលោតស្រ្តុបចូលមកគេចផុតពីដកគាត់ភ្លាមក៏ខ្វាំទ្រូង គាត់ទៀត ៗ

វូគារស៊ីមានមាឌធំខ្ពស់ប្រៀបទៅនឹងតាចាស់ចាបស្គមឈរត្រឹមស្មាគាត់ប៉ុណ្ណោះ តែតាចាស់ មាន វិជ្ជាកាចសាហាវវ៉ៃយកុកគ្មានសំបែរសោះ ៗ គាត់ឃើញតានេះលោតចូលមកវាំងកម្រោល ដូច្នេះ ក៏ភ្ញាក់ព្រឺតប្រញាប់ថយក្រោយក្នុះបូវតែខ្វាកអាវគាត់ត្រូវក្រញាំដៃតានោះចាប់ រហែកមួយដុំ ស្រេច ៗ

វូគារស៊ីមានអារម្មណ៍ត្រជាក់ពោះស្រឹត ៗ តែគ្មានពេលពិនិត្យមើលទេ, ម្ដីម្ដាផ្គោបដៃទាំងពីរយារ ដកសំពងសៀតផ្កាទាំងពីរនៃតាចាស់នោះវិញ ៗ តាចាស់មិនគេចមិនរង បែរជាជម្រុញខ្លួនឲ្យជ្រុល ទៅមុខទៀត ហើយដៃទាំងពីរវះត្រូវខ្លួនវូគារស៊ីទាំង ១ ! លាន់សូរក្រាក ១ មិនដឹងជាបាក់ឆ្អឹង អស់ប៉ុន្មានទេ ! ឯកងកាយវូគារស៊ីក៏ដាំផ្ងួងធ្លាក់ចុះមកក្រោម ៗ ចំណែកលីតាយានដែលត្រូវ ខ្លាញ់ស្រួសជើងនោះទំងប្រែទៅឡាតកោតគួរ តែដោយជើងគាត់មានរបួស មិនអាចលោតទៅលើដំបូល ផ្ទះបានម្យ៉ាងទៀតដឹងថា តាចាស់ស្គមចាបឈ្មោះចុងមុខនេះក្ដីក្ដាំងណាស់មិនចូលចិត្តឲ្យគេចូលទៅ ជួបគាត់ទេ បានជាគាត់ឈរមើលតែមើលពីក្រោម ៗ លុះឃើញវូគារស៊ីរបៀលធ្លាក់ចុះមក លីតា យានក៏លោតផ្លោតដូចសត្វខ្លាព្រៃយោរម្ដងទាំងពីរចាក់ចំតម្រង់ពោះវូគារស៊ី ហើយបានចិត្តឈរលើប ក្នុងក្ដាយ ៗ ជួវប៉ុប្រែកមកពីលើថា :

- កុំសម្លាប់វា !

តែយឺតពេល ហើយវត្តារ៉ុត្រូវពីរទម្លាក់ម្ដងពេចនៅរស់បានទៀត ។ ខណៈនោះស្រាប់តែស្រមោលមនុស្សលោតភ្លែត ហើយលីតាយានស្រែកអូយ ... ទ្រេតទ្រោតថយក្រោយបុន្មានជំហាន ដោយដើមទ្រូងជាប់ជក់ដែកពីរចុះដល់ខ្នងមានឈាមហូរចេញតាមមុខរបួសក្រហមច្រាល ។ ថយបានតែបុន្មានជំហានក៏ធ្លាវជើងដួលប្រូសទៅ ! គឺជាការវាយប្រហារចុងក្រោយនៃវត្តារ៉ុដែលធ្លៀតពេលសត្រូវភ្លេចខ្លួនលោតទៅប្រហារនោះឯង ។

ពួកជំរំកាំបិតមាស ភ័យណាស់ស្ទុះស្រចូលមកជួយគ្រាហ៍ តែលីតាយានដាច់ខ្យល់ស្លាប់បាត់ទៅហើយ ។

ចំណែកតាចាសចូវមុមិនសូវរវល់នឹងការស្លាប់របស់ លីតាយានទេ គាត់បញ្ចេញទឹកមុខសោះកក្រោះចូវមុទៅចាប់លើក វត្តារ៉ុឃើញលែងដកដង្ហើមទៅហើយ ! ចូវមុជ្រួញចិញ្ចើមគំហកថា:

- បកអាវវាពិនិត្យឲ្យសព្វគ្រប់មើល !

សេនាជូនគាត់ឆ្លើយបាទស្ទុះចូលមកចាប់បកអាវគាត់ ឃើញមានសំពាយមួយនៅក្រោយខ្នងសម្រាប់ធ្វើឲ្យខ្នងកោងនោះ ។ សេនាអាវខ្មៅពីរនាក់ប្រញាប់ស្រាយបន្ទឹងនោះឃើញមានកញ្ចប់មួយទៀត ។ គេស្រាយមួយស្រទាប់ហើយ ហើយមានស្រទាប់មួយទៀត... ពេលនេះចូវមុមានទឹកមុខរីករាយ រេះតែនឹកអរក្នុងចិត្តថា:

- នៅទីហ្នឹងហើយ ! ហ្នឹងហើយ !

គេស្រាវជ្រាវដប់ស្រទាប់កាន់តែតូចទៅ ។ នៅសល់តែកូនកញ្ចប់មួយតូចសោះ ។ ចូវមុក៏កញ្ឆក់យកមកគំហកថា :

- បានហើយ ! ទៅរកក្នុងផ្ទះវាម្ដងវិញ !

- ពួកជនអាវខ្មៅទាំងនោះក៏ស្រែកអ៊ឹងចូលទៅក្នុងផ្ទះលក់នំដែលមានតែពីរបន្ទប់,បើកកកាយវាយបែកចានក្បាននតុទូខូចខ្ទេចខ្ទីគ្រាក់តេចេញមក ! ចូវមុចេះតែស្រែកពីក្រៅថា :

- រែករកឲ្យបានល្អិតល្អន់ ! កុំប្រហែសឲ្យសោះ !

រហូតដល់ពេលយប់មើលអ្វីលែងឃើញ ជនអាវខ្មៅទាំងនោះនាំគ្នាដុតភ្លើងចំកី សូម្បីតែ

ចង្ក្រានក៏គេរើកកាយគ្មានចន្លោះមួយកន្លែងណាដែរ ។

ពេលដែលយប់ងងឹតមើលអ្វីលែងឃើញនោះស្រាប់តែមានកូនដៃមួយប្រឡាក់ប្រឡូស លូកចេញពីផ្ទាំងបាក់ថែកមួយនៅគាប់ជ្រុងផ្លូវលបចាប់យកដំបងទ្វាញ៉ៃដែលធ្លាក់ក្បែរចង្កូវចុំកនោះ ហើយដកដៃសង្រួមទៅវិញ ។ នេះជាក្មេងស្គមបោចកព្រុយប្រមាណជាដប់ពីរឬដប់បីឆ្នាំប៉ុណ្ណោះ ។ ក្មេងនេះអត់បាយមួយថ្ងៃហើយអស់កម្លាំងឈប់សម្រាកក្រោយផ្ទាំងផ្ទះគេតាំងពីថ្ងៃម៉្សិល ។ ពេលដែលឃើញគាយានបោលចំលំដៅរកទាវតុនោះមានធ្លាក់ក្រមួនចង្កូវចំក ក្នុងពាំងខ្លួនក្មេងស្គមនេះក៏ចាំងបកលើងនោះមិនព្រិចភ្នែក លុះចង់លូកដៃទៅយកមកស៊ីដែរតែក្រឡេកទៅឃើញមនុស្សឈរពាសពេញតាមផ្លូវ បានជាភ័យស្ងៀមមិនហ៊ានកម្រើកខ្លួន ។

សាកសពកម្មករនៃគៀមដែលត្រូវសេះជាន់ស្លាប់នោះក៏នៅក្បែរនេះដែរ ។ ក្រោយមកសពនូការស៊ីចង្កៀងលីគាយានក៏ដួលនៅក្បែរទីនោះទៀត ហេតុដល់ពេលងងឹតដែលពន្លឺភ្លើងក៏ចាំងមិនដល់ ទើបក្មេងស្គមនោះដាច់ចិត្តលូកចាប់ទំនោះមក ។ ការស្រេកឃ្លានក៏ពុំនឹកមានឥទ្ធិពលហើយខ្លាំងក៏មិនរវល់នឹងនំដែលប្រឡាក់ដីនោះទេក៏ចាំមួយមាត់បៀមក្នុងមាត់មិនចំពារ ខ្លាចសម្លេងចំពារនេះលេចឮដល់ពួកជនការទ្វារដែលកាន់កាំបិតគ្រប់ដៃនោះ ។ ក៏បៀមក្នុងមាត់ហើយនោះមិនទាន់លេបក៏ហាក់ដូចជាឃ្លាំងឃ្លានខ្វះដែរ ។

ខណៈនោះដុនត្សេវខ្មៅចាំងអស់រើកកាយសព្វគ្រប់ សូម្បីតែកប្រាលផ្ទះក៏គាស់គ្មានសល់ ទើបគាស្តមនោះស្រែកថា :

– ប្រមូលគ្នាត្រឡប់ទៅវិញ !

ពួសូវតែសមួងកញ្ចាត្រចង្ខាច និង ស្លូវជើងសេះពង្កាំ . . គេនាំគ្នាចាកចេញពីទីក្លុមតូចនោះជាបន្តបន្ទាប់ ដោយយកចាំងសពលីគាយានទៅជាមួយផង ។ ដល់ស្ងាត់ស្លូវជើងសេះមួយសន្ទុះធំ ទើបក្នុងភូមិនោះមាន ពួ សូរសម្លេងមនុស្សតិចៗព្រោះអ្នកស្រុកខ្លាចពួកពាំងនោះត្រឡប់មកវិញ បានជាមិនហ៊ាននិយាយគ្នាខ្លាំងពេក ។

ចាស់គៀមទិងកម្មករម្នាក់ទៀត ស្ទុះចេញមកលើកសាកសពកម្មករម្នាក់នោះដាក់លើគ្រែ ហើយមិនទាន់បិទទ្វារគៀមជាបន្ទាន់គ្មានអ្នកណាហ៊ានចេញមកក្រៅឡើយ ។ ពួសូវតែសម្លេងបិទទ្វារគ្រាំងគុំគងឹត មិនយូរប៉ុន្មាននៅតាមផ្លូវគ្មានស្រមោលមនុស្សហើយក៏គ្មានសូរសម្លេងប៉ុណ្ណោះដែរ ។

ឯកូនសួមនោះវិញនឹកខ្លាចនឹងសភាពស្ងាត់ស្ងៀមបែបនេះណាស់ ម៉្យាងទៀតឃើញសាកសពគ្រាវ ក៏នៅដេកស្ងៀមគ្មានអ្នកណារវល់សោះក៏នឹកខ្លាចកាន់តែខ្លាំងឡើង ។ រាំចំពោះនំដែលនៅក្នុងមាត់តិចៗទើបលេបនំនោះទៅក្នុងពោះប្រុងនឹងទាំមួយម៉ាត់ទៀត ស្រាប់តែក្រឡេកទៅឃើញសាកសពគ្រាវអ៊ុតម្រើកខ្លួន ។ កូនសួមភ្ញាក់ព្រើតយកដៃញីភ្នែកសម្លឹងមើលម្តងទៀតឃើញសាកសពនោះក្រោកអង្គុយសន្សឹមៗ ។ រាក់យរន្ធត់ក្រលែងនឹកឃើញរឿងខ្មោចទៅដែលគេព្រាប់ប្តូរជំណាលព្រាប់ ។

ស្រាប់តែសពនោះក្រោកឈរតែកូតធ្វើឲ្យកូនសួមញ័រខ្លួនរណ្តំធ្មេញលាន់គឹក ៗ គឹក ៗ

ខ្មោចនោះនោះបែរមកតែមើលមិនឃើញរាទេព្រោះកូនសួមពួននៅក្រោយជញ្ជាំងផ្ទះ ។ ក្នុងព្រះចន្ទដែលបាំងមកពីចំហៀងធ្វើឲ្យកូនសួមមើលឃើញយ៉ាងច្បាស់ គឺខ្មោចនោះ [illegible] មាត់ចម្លែកដែកចាំងពីរទៅបាត់ជាប់ក្នុងពោះតាំងទៅឡើយ ។

កូនសួមចាំទាំមាត់មិនឲ្យស្រួសមេនីងរួបក្តិបសោះ ។ បន្ទាប់មកឃើញខ្មោចទៅចាប់ពពីរលូកដៃការពីស្លាបបះនិមួយ គឺចាប់ប្រចាច់ហោយដៃទាំងពីរបែកខ្ទេចទើបគ្រវាត់ហោល ។ បញ្ចប់មកកាប់បះនិមួយទៀតគឺចាប់ហែកហើយហោះហោលទៀត ! កូនសួមភ័យលោះព្រលឹង ព្រោះខ្មោចនោះនោះចេះកាស្លាបសត្វទាំងប៉ុនៗមិនផ្សេងពីគ្នាឡើយ ដល់ស្លាបនិមួយដាច់ខ្ទាញ់ ទើបចាប់ញីបែកហោះហោល ។

ពេលនោះគេស្លាបចុះស្លាបឡើងកាន់តែបកជ័តទឹក កូនសួមឃើញខ្មោចនោះតែងតែចូលមក [illegible] យកស្អុះភ្នែកស្អុះតែងដៃ តែកាន់តែងដៃកម្រើកខ្លួនមិនរួចសោះ ។ ខ្មោចនោះមានកាយរីកពើតណាស់ពេលដែលដងទាំងនោះតែកផ្ទះលក់នឹង គេបានលើកក្តារពាក់ហោះហោលមកក្រៅតាក់តេញធី, ខ្មោចនោះទៅកាត់សម្លាប់ម្តងៗមកហាប់ហែកហោះហោលជាតសាបង់ ប្រហែលកន្លះម៉ោងទើបអស់ !

លុះស្លាបចំនួនបះនំទើបខ្មោចនោះបែរក្បាលមើលជុំវិញ ហាក់ចង់រកអ្វីទៀតកូន [illegible] ក្រឡេកឃើញសភាពមួយ គឺភ័យពេកព្រលឹងហួងទៀត ព្រោះរាំពូនក្រោយជញ្ជាំងផ្ទះឃើញស្រមោលខ្លួនឯង [illegible] លើដីច្បាស់ក្រឡែក មានសក់ក្បាលកន្រ្តឹងរឿងខ្មោចទៅ តែរាំមិនដឹងជាស្រមោលរាទេ ។ ដំ ឃើញខ្មោចនោះកំពើតដើងម្តងទៀត រាក់យស្ទុះវែងចេញក្រៅស្រុកហៅមើល ។

ខ្មោចឆៅ ស្រែកថា:

- កុំខ្លាច ! កុំខ្លាច !

ព្រមពាំងរលាកផ្ទាតៗសំដៅមក ។ ដោយភ័យពេកកូនស្ទូមក៏ដំពប់ជើងដួលផាំផ្លូងប្រូស ខ្មោចឆៅក៏លូកដៃសង្កត់ខ្នងរាវរកកូនស្ទូមហើសណាស់, ប្រមៀលខ្លួនគេចទៅម្ខាងហើយស្ទុះរត់ទៅមុខទៀតភ្លាម ។ ខ្មោចឆៅក្រោកភ្លាមមិនរួចទេ ទាល់តែរំព្រដេគ្រដរមួយសន្ទុះទើបរួច ។ ខ្មោចឆៅមានជើងវែងណាស់ពោះជាទ្រេតទ្រោតក៏ដើរលឿនដែរ ។ គ្រាន់តែ៤-១០ជំហាន ប៉ុណ្ណោះក៏ដេញទាន់កូនស្ទូមស្រេច ។ ស្ទូមល្អិតរត់ទៅជិតដើមឈើមួយក៏គិតឃើញថា «ខ្មោចឆៅមិនចេះដើរបត់ទេ ម្ល៉ោះហើយគិតរត់ជុំវិញដើមឈើនេះសាកមើល» ។ ខណៈនោះស្រាប់តែគរភាវភិតក៏ផ្ទុះ ដោយវាត្រូវខ្មោចឆៅចាប់យួរផុតពីដី ។

- ឯងលួចទំពាំងខ្ញាញ់អញមែនទេ ?

- កូនស្ទូមមិនអាចប្រកែកបាន ក៏ងក់ក្បាល ។ ខ្មោចឆៅសួរទៀត:

- ឯង . . . ឯងស៊ីអស់ហើយឬ ?

កូនស្ទូមងក់ក្បាលម្តងទៀត ។ ខ្មោចឆៅក៏លូកដៃទៅចាប់អាវវាហែកខ្វាក ហើយពោលបន្ទុះ:

- អញវះពោះឯងកកាយទំចេញមកវិញមិនខាន !

កូនស្ទូមភ័យព្រលឹងពុងសក់ ពោលទាំងញញើញញ័រថា:

- ខ្ញុំ . . . ខ្ញុំ . . . ខាំបានតែមួយមាត់ទេ !

ដោយភ័យស្ទន់ពេកវាភ្លេចគិតថា ហេតុអីក៏ខ្មោចឆៅនេះចេះនិយាយស្តី ? តាមការពិតវូតាវអ៊ុ ដែលត្រូវចូរមុខពោះពីដៃគ្រូចំដើមទ្រូងនិងត្រូវលីតាយានទម្លុះពោះទៀតនោះ គ្រាន់តែសន្លប់ទេ មិនយូរប៉ុន្មានក៏ភ្ញាក់ដឹងខ្លួនឡើងវិញ ។ ពោះមិនមែនកន្លែងសំខាន់ឡើយបើពាក់ត្រូវ ហើយឈាមមិនទាន់ហូរចេញមកមិនដាច់ខ្យល់ស្លាប់ភ្លាមទេ ។ ម្យ៉ាងទៀតវូតាវអ៊ុបានចាប់ចិត្ត ផិតអារម្មណ៍និងវត្ថុមួយយ៉ាងសំខាន់, មានស្មារតីឡើងវិញភ្លាមហើយដឹងថាពួកជំរំកាំបិតមាសចាកចេញ ទៅអស់ហើយគាត់ក៏ម៉ីម្ហារលុះណោំងទំរកវត្ថុដែលលាក់ក្នុងបំពង់ដោយមិនរវល់ទឹងមុខរបួសទេ ។ ព្រោះអីគាត់ក្លែងខ្លួនជាមនុស្សគមមករស់នៅក្នុងភូមិហ្វូវជាននេះក៏ដើម្បីរក្សាការពារវត្ថុនោះឯង ។ គាត់

សូមអភ័យទោស ដោយបាត់ទំព័រទី១១ ដល់ទី ១៤

រួចគាត់នឹកក្នុងចិត្តថា គេមានអាយុតិចជាងអញតែបែរជាហៅគ្រូមាអញថាបងទៅវិញ ដូច្នេះហាក់ដូចជាបង់លើកឋានៈឲ្យខ្ពស់ជាងអញផង ៗ គួរបញ្ជាក់ថាឋានៈនៃពិភពគុនសំខាន់ណាស់បើក្នុងជួបប្រទះនឹងចាស់ ត្រូវតែមានការគោរពជានិច្ច ហើយបើចាស់ទុំដែលមានឋានៈខ្ពស់ជាងនោះ បញ្ជាឲ្យធ្វើការអ្វីដែលមានឋានៈទាបជាងមិនអាចប្រកែកបានឡើយ ។ ប៉ុន្តែព្រឹទ្ធស៊ីឈីងឃើញគាត់ប៉ោះទឹកមុខក៏ដឹងចិត្តគាត់ ទើបសើចហាសៗ:

-អូ! អត់ទោស ! កាលប្រជុំគ្នាលើភ្នំហួសាន លោកបងជួងបាននិយាយពីវិជ្ជាយុទ្ធសិល្បៈរបស់ក្រុមលោក ខ្ញុំពីរនាក់ប្ដីប្រពន្ធស្ងើចសរសើរណាស់ ឥឡូវខ្ញុំមានពាក្យមួយហ៊ានចង់ស្នើលោកប្អូនចូវ ៗ សូមលោកប្អូនកុំប្រកាន់ណា !

គេហៅចូវមុជាលោក «ប្អូន» ដូច្នេះគឺបញ្ជាក់ឲ្យដឹងថាគាត់តាំងខ្លួនជាចាស់ទុំជាងចូវមុំមែនៗ ចូវមុហួសចិត្តដោយគាត់មានចំណាស់ជាងគេក៏ធ្វើជាតបថា:

- បើសិនរឿងនេះ ជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំអាចយល់ព្រមបានឡើតែលោកទាំង ២ មានប្រសាសន៍មកចុះ តែបើសិនជារឿងនេះមានការពាក់ព័ន្ធដល់ផ្នែកក្នុងជំរំខ្ញុំ ខ្ញុំមានឋានៈទាបមិនអាចទាក់ទងការបានឡើយ !

ស៊ីឈីង នឹកក្នុងចិត្តថា កញ្ចាស់នេះប្រសប់និយាយមែន, រាំងរោះខ្លួនឲ្យរួចស្រឡះតែម្ដង ៗ គាត់ពោលថា :

- យើងគ្មានការទាក់ទងអ្វីនឹងជំរំលោកទេ តែខ្ញុំចង់សុំស៊ើបរឿងមួយពីលោកប្អូន ៗ ខ្ញុំពីរនាក់ប្ដីប្រពន្ធដេញតាមមនុស្សម្នាក់តាំងពីស្រុកវង់គុនហុតមកដល់ទីនេះ ជននោះឈ្មោះ វូតាវអ៊ី ប្រើដកដែកមួយតូចជាអាវុធមានមាឌធំខ្ពស់ អាយុប្រមាណជា៣០ឆ្នាំបាយ ។ ឮថាប៉ុន្មានឆ្នាំនេះគេក្លែងខ្លួនជាមនុស្សគមមកលាក់ខ្លួនពួនអាត្មានៅម្ដុំនេះឯង តើលោកប្អូនមានឮដំណឹងពីជននេះទេ ?

ស៊ីឈីងគ្រាន់តែបញ្ចេញឈ្មោះវូតាវអ៊ីភ្លាមពួកពលសេនានៃជំរំកាំបិតមាស រំជើបរំជួលគ្រប់ៗគ្នាទុះដែលមិនទាន់បរិភោគរួចក៏ទម្លាក់ចានចុះ ៗ ចូវមុនឹកក្នុងចិត្តថា «ឯងមកពីខាងកើតប្រហែលជាបានប្រទះឃើញសពវូតាវអ៊ីហើយ បើសិនជាមិននិយាយទេហាក់ដូចជាយើងកំសាកពេក»

គិតហើយ, គាត់សើចហាសៗ, តបវិញថា:

-លោកប្រុសនិងលោកស្រី ! ខ្ញុំសែចូវមានវិជ្ជាទន់ខ្សោយមែនតែបានជួយបំពេញបេសកកម្មយ៉ាង

ពិសេសជំនួសលោកប្រុសនិងលោកស្រីនេះ, សុំដាក់ចង្កៀងកែវមាសបានត្រឡប់ទៅវិញហើយ ។

គាត់ពោលបណ្ដើរសម្លឹងមើលទឹកមុខប៉ូលីសបណ្ដើរ ។ ឯស៊ីឈើងស្ដាប់សំដីដឹងថាគាត់ជាមនុស្សមានប្រាជ្ញាភ្លឺថ្លាណាស់ដែរ ក៏សើចញឹមៗតបទៅវិញថា:

វូតាវ៉ុនេះគ្មានអ្វីពាក់ព័ន្ធនឹងខ្ញុំទេ ហើយក៏មិនដែលនិយាយថាគេបានធ្វើការអ្វីធ្ងន់ធ្ងរចំពោះខ្ញុំដែរ ខ្ញុំតាមមករកជននេះគឺមានបំណងលើវត្ថុមួយ សូមលោកប្អូនចូវកុំសើចអី !

ចូវមុះថ្ងោះទឹកមុខបន្តិចហើយប្រែមកធម្មតាវិញ ដោយសើចហើយពោលថា :

– លោកប្រុសនិងលោកស្រីបានដំណឹងហើយមែន, ដំណឹងនេះដំរីកាំបិតមាសខ្ញុំបាន ទើបនឹងបានទទួលដែរ ។ ក៏ ! មិនដឹងជាមនុស្សអាក្រក់ណាចេះតែផ្សាយពាក្យចចាមអារ៉ាម ធ្វើឲ្យលោកវូតាវ៉ុស្លាប់ឥតប្រយោជន៍ ។ ពួកយើង២,៣នាក់គ្មានបានផលប្រយោជន៍អ្វីសោះ ហើយទៅវិញច្បាស់ជាលោកបងបន្ទោសថាខ្ញុំធ្វើការមិនកើតហើយ ។ ម៉្យាងទៀតក្នុងពិភពគុនច្បាស់ជាយល់ច្រឡំថាដំរីកាំបិតមាសយើងខ្ញុំរកបានវត្ថុនោះពុំខាន ។ នែលោកប្អូនចាវ ឯងមករៀបរាប់ព្រឹត្តិការណ៍វិលយើងបានប្រហារជនត្រកូលវ៉ូនិងការដែលកើតនៅក្នុងផ្ទះលក់ទំនោះ ជម្រាបលោកប្រុសនិងលោកស្រីឲ្យបានច្បាស់លាស់ទៅមើល !

ជនម្នាក់ដែលមានមាឌតូចខ្ពស់ស្គមចេញមកពោលថា :

– លោកនាយត្រកូលវ៉ូ យារដៃតាំង ២ ចះអាត្រកូលវ៉ូធ្លាក់ពីលើដំបូលផ្ទះ ធ្វើឲ្យវាបាក់ឆ្អឹងខ្នងខ្ទេចហើយស្លាប់មួយរំពេច...

ជននោះក៏យកព្រឹត្តិការណ៍ ដែលពួកគេដែកនៅផ្ទះលក់ទំនោះយ៉ាងក្បោះក្បាយគ្រាន់តែលាក់ទុករឿងដែលចូវមុយកកូនកញ្ចប់មួយពីខ្លួនវូតាវ៉ុប៉ុណ្ណោះ ។

លុះស្ដាប់ចប់ហើយស៊ីឈើងក៏ក្បាលទឹកថាចូវមុនេះ គ្រាន់តែឃើញពួកយើងមកដល់ ក៏សំដែងអាការៈប្រុងប្រយ័ត្នហាក់ដូចជាបារម្ភណាស់ ។ គុម្ពដ្ឋានសាកសួរ និងដំរីកាំបិតមាស គ្មានគំនុំអ្វីសោះទេ បើសិនជាគេមិនទាន់រកវត្ថុនោះបានទេ ហេតុអ្វីក៏គេប្រុងប្រយ័ត្ននឹងពួកយើង២នាក់ប្ដីប្រពន្ធនេះម្ល៉េះ? ស៊ីឈើងយល់ទៀតថា បើសិនជាពួកនេះពិតជារកឃើញវត្ថុនោះមែនគឺច្បាស់ជាលាក់ទុកក្នុងខ្លួនចូវមុពុំខាន ។

**(នៅមានត)**

ដំកល់ទុកតាមលេខ ២៥៧ ចុះថ្ងៃទី ១៤-៤-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers